# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧ សហវ. អគព

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១១

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ មេត្តាជ្រាបថា: ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ត្រូវចាប់អនុវត្តពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

**<u>ពន្ធនេះត្រូវបានលើកលែងមិនប្រមូលចំពោះ :</u>**

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះរបស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត) ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបញ្ជាក់ការបង់ពន្ធសម្រាប់ឆ្នាំ២០១០ សម្រាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១០រួចហើយ ។ ក្នុងករណីបាត់បង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១០ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសម្រាប់ឆ្នាំ២០១០ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ នៃទីកន្លែងដែលយានយន្តនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១០ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណា ដែលពុំមានបង្កាន់ដៃបង់ពន្ធឆ្នាំ២០១០ទេនោះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវបង់ពន្ធសម្រាប់ឆ្នាំ២០១០ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ លើកលែងតែទោចក្រយានយន្ត

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ប៉ុណ្ណោះ ដែលពុំចាំបាច់ឱ្យម្ចាស់បង្ហាញបង្កាន់ដៃបង់ពន្ធឡើយ គឺគ្រាន់តែទិញប័ណ្ណបង់ពន្ធទោចក្រយានយន្តយកទៅបិទនឹងទោចក្រយានយន្តរបស់ខ្លួនជាការស្រេច ។ ក្នុងករណីទោចក្រយានយន្តណាមួយគ្មានបិទប័ណ្ណបង់ពន្ធ ត្រូវចាត់ទុកថាទោចក្រយានយន្តនោះមិនទាន់បានបង់ពន្ធនៅឡើយ ។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលប័ណ្ណបង់ពន្ធមួយសន្លឹកសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ និងបង្កាន់ដៃបង់ពន្ធមួយសន្លឹកទៀត ។ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសម្រាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

ចំពោះមធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែកមួយ និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសនោះប្រកាសបង់ពន្ធលើប្រាក់ចំណេញអាករលើតម្លៃបន្ថែម... ជារៀងរាល់ខែ ។

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ត្រូវអនុវត្តចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ តទៅ ។

ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ត្រូវមានវិក្កយបត្រ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬប័ណ្ណសំគាល់យានយន្តថតចំលងភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំ២០១១នេះ ។

សម្រាប់ឆ្នាំ២០១១នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផលិតប័ណ្ណលតាបត្រពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយមានគុណភាព មានសញ្ញាចំណាំ និងលេខកូដ ដែលអាចផ្ទៀងផ្ទាត់ ឬប្រើប្រាស់ឧបករណ៍ស្វ័យប្រវត្តិ ដើម្បីត្រួតពិនិត្យលក្ខណៈពិតប្រាកដ និងក្លែងក្លាយរបស់លតាបត្រទាំងនោះ ។ ដូច្នេះ ដើម្បីជៀសវាងការទិញប័ណ្ណបង់ពន្ធក្លែងក្លាយនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមអញ្ជើញលោក-លោកស្រី ជាម្ចាស់យានយន្តទៅប្រកាសបង់ពន្ធដោយផ្ទាល់នៅតាមទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ ដែលនៅជិតគេហដ្ឋានលោក-លោកស្រី ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាប្រញាប់ប្រញាល់ រួសរាន់អញ្ជើញទៅបង់ពន្ធនេះឱ្យបានមុនថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ កុំបីខាន ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់